01322646

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception):
29 / 08 / 2016
ម៉ោង (Time/Heure): 14:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

002/19-09-2007-ECCC/TC
**E1/444**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

# <u>កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី</u>

## <u>សាធារណៈ</u>

## សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសដ

## ថ្ងៃ ច័ន្ទ ទី ២៧ ខែ មិថុនា ឆ្នាំ ២០១៦

## **សវនាការលើភ័ស្តុតាង - ថ្ងៃ ៤២៥**

រៀបចំដោយ៖ កញ្ញា ជា ស៊ីវហ័ង និង Evelyn CAMPOS SANCHEZ

| <u>កំណត់ហេតុអ្នកចូលរួម</u> |
| --- |
| ចំពោះមុខ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម Jean-Marc LAVERGNE, ចៅក្រម យូរ ឧត្តរា ចៅក្រម ធូ មណី, ចៅក្រម Martin KAROPKIN |
| ចៅក្រមបម្រុង៖ |
| ក្រឡាបញ្ជី ៖ កញ្ញា ជា ស៊ីវហ័ង និង កញ្ញា Evelyn CAMPOS SANCHEZ |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោក William SMITH, លោក សេង លាង, លោកក Nicholas KOUMJIAN |
| ជនជាប់ចោទ៖ លោក នួន ជា (ពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ), លោក ខៀវ សំផន |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ នួន ជា៖ លោក Victor KOPPE, លោក លើវ សុវណ្ណា, លោកស្រី Doreen CHEN, លោក សុន អរុណ |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ ខៀវ សំផន៖ លោកស្រី Anta GUISSÉ, លោក គង់ សំអុន |
| ក្រុមមេធាវីប្រចាំការសម្រាប់ជនជាប់ចោទ ខៀវ សំផន៖ លោកស្រី ទូច វរល័ក្ស, លោក Calvin SAUNDERS |
| មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖ លោកស្រី Marie GUIRAUD , លោក ពេជ អង្គ, លោកស្រី |

| |
|---|
| ទី ស្រ៊ុនណា, លោកស្រី ស៊ីន សុវ៉ន, លោក វ៉ែន ពៅ, លោក ឡៅ ជុនធី |
| ដើមបណ្ដឹង/សាក្សី/អ្នកជំនាញ៖ កាំង ហ្គេកអ៊ាវ *ហៅ* ឌុច (2-TCW-916) |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក អ៊ុច អរុណ, លោកស្រី សួ សុទ្ធាវី |
| ផ្សេងៗ៖ លោក កែវ វ៉ាត, លោក ឡាយ ណារ៉ា, កញ្ញា សួន ដារ៉ាវស្មី, កញ្ញា Hannha Kim |

| **<u>ពេលវេលាទូទៅរបស់តុលាការ៖</u>** | | |
|---|---|---|
| ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១៦ | ចាប់ផ្ដើមម៉ោង៖ ០៩.០៣ | បញ្ចប់ម៉ោង៖១០.៤៧ |
| សម្រាកពេលព្រឹក | ចាប់ផ្ដើមម៉ោង៖ | បញ្ចប់ម៉ោង៖ |
| សម្រាកថ្ងៃត្រង់ | ចាប់ផ្ដើមម៉ោង៖ | បញ្ចប់ម៉ោង៖ |
| សម្រាកពេលរសៀល | ចាប់ផ្ដើមម៉ោង៖ | បញ្ចប់ម៉ោង៖ |
| | ចំនួនម៉ោងសរុបរបស់តុលាការ៖ | ១ ម៉ោង ៤៤ នាទី |

| **<u>កិច្ចដំណើរការនីតិវិធីផ្សេងទៀត</u>** | | | |
|---|---|---|---|
| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្ដើម | ម៉ោងបញ្ចប់ |
| ការប្រកាសបើកកិច្ចដំណើរការសវនាការ និងការប្រកាសពីវត្តមានរបស់ភាគី | អង្គជំនុំជម្រះ<br>ក្រឡាបញ្ជី | ០៩.០៣ | ០៩.០៦ |
| សំណើរបស់ នួន ជា ស្នើសុំតាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ | មេធាវីការពារក្ដី នួន ជា | ០៩.០៦ | ០៩.០៨ |
| ការបន្តតាំងសំណួរទៅសាក្សី កាំង ហ្គេកអ៊ាវ *ហៅ* ឌុច (2-TCW-916) | អង្គជំនុំជម្រះ<br>មេធាវីការពារក្ដី នួន ជា | ០៩.០៨ | ១០.១២ |
| សារណាផ្ទាល់មាត់ពាក់ព័ន្ធនឹងសំណើរបស់មេធាវីការពារក្ដី ខៀវ សំផន (E420) | អង្គជំនុំជម្រះ<br>មេធាវីការពារក្ដី ខៀវ សំផន<br><br>មេធាវីការពារក្ដី នួន ជា<br>សហព្រះរាជអាជ្ញា<br>សហមេធាវីនាំមុខ | ១០.១២<br>១០.១៥<br>១០.៣៦<br>១០.២៧<br>១០.៣១<br>១០.៣៣ | ១០.១៥<br>១០.២៧<br>១០.៤០<br>១០.៣១<br>១០.៣៣<br>១០.៣៦ |

**សេចក្តីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖**

**ការប្រកាសបើកកិច្ចដំណើរការនីតិវិធីសវនាការនិងការប្រកាសពីវត្តមានរបស់ភាគី**

ប្រធានអង្គជំនុំជម្រះប្រកាសបើកកិច្ចដំណើរការនីតិវិធីសវនាការ។ ក្រឡាបញ្ជីរាយការណ៍ថា គ្រប់ភាគីទាំងអស់មានវត្តមាន លើកលែងតែចៅក្រម Fenz និងចៅក្រម យ៉ា សុខន ដែលអវត្តមាន។ ជនជាប់ចោទ នួន ជា មានវត្តមាននៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ។

**សំណើរបស់ នួន ជា សុំតាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ**

អង្គជំនុំជម្រះសម្រេចអនុញ្ញាតតាមសំណើរបស់ជនជាប់ចោទ នួន ជា ដែលបានស្នើសុំលះបង់សិទ្ធិចូលរួមកិច្ចដំណើរការនីតិវិធីដោយផ្ទាល់ក្នុងសាលសវនាការ និងអនុញ្ញាតឱ្យគាត់តាមដានកិច្ចដំណើរការនីតិវិធីសវនាការពីបន្ទប់ឃុំខ្លួនស្ថិតនៅខាងក្រោមសាលសវនាការ។

**ការបន្តតាំងសំណួរទៅសាក្សី កាំង ហ្កេកអ៊ាវ *ហៅ*ឌុច (2TCW-916)**

មេធាវីការពារក្តី នួន ជា បានបន្តការតាំងសំណួរទៅកាន់សាក្សី កាំង ហ្កេកអ៊ាវ *ហៅ* ឌុច (2TCW-916)។

**សារណាផ្ទាល់មាត់ពាក់ព័ន្ធនឹងសំណើ របស់មេធាវីការពារក្តី ខៀវ សំផន (E420)**

អង្គជំនុំជម្រះបានស្តាប់សារណាឆ្លើយតបពីភាគីផ្សេងៗទៀត ទៅនឹងសំណើរបស់មេធាវីការពារក្តី ខៀវ សំផន (E420) ដើម្បីអាចឱ្យអង្គជំនុំជម្រះបំភ្លឺអំពីវិសាលភាពនៃប្រធានបទជំនុំជម្រះ ការបោសសម្អាតផ្ទៃក្នុង ហើយនិងដើម្បីអាចឱ្យអង្គជំនុំជម្រះសម្រេចអំពីការកោះហៅសាក្សីមួយចំនួនពាក់ព័ន្ធនឹងអង្គហេតុនេះ។

មេធាវីការពារក្តី ខៀវ សំផន បានរម្លឹកដល់ភាគីផ្សេងៗថា សំណើនេះគឺជាសំណើសុំឱ្យពិចារណាឡើងវិញ អនុលោមតាមវិធាន ៩៨(២) នៃវិធានផ្ទៃក្នុង អំពីយុត្តាធិការរបស់អង្គជំនុំជម្រះពាក់ព័ន្ធនឹងនឹងអង្គហេតុ ការបោសសម្អាតផ្ទៃក្នុង។ មេធាវីការពារក្តីមិនយល់ស្របទៅនឹងសំអាងហេតុរបស់អង្គជំនុំជម្រះក្នុងការកោះហៅសាក្សីដែលមានរហស្សនាម 2-TCW-1005 ដោយសារតែសាក្សីរូបនេះត្រូវមកផ្តល់សក្ខីកម្មពាក់ព័ន្ធនឹងការបោសសម្អាតនៅក្រចេះ។ មេធាវីការពារក្តីបានអះអាងថា ការបោសសម្អាតគឺមិនមែនជាឧក្រិដ្ឋកម្មនោះទេ ប៉ុន្តែគឺជាពាក្យដែលបានប្រើប្រាស់ដោយសហចៅក្រមស៊ើបអង្កេតនៅក្នុងដីកាដំណោះស្រាយ។ មេធាវីការពារក្តីបានលើកឡើងថា យុត្តាធិការរបស់អង្គជំនុំជម្រះមិនគួរលើសពីអ្វីដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅស៊ើបសួរ និងដីកាដំណោះស្រាយនោះឡើយ ពោលគឺ ព្រឹត្តិការណ៍

ដែលបានកើតឡើងនៅភូមិភាគ ឧត្តរ ក្នុងឆ្នាំ ១៩៧៦ និងព្រឹត្តិការណ៍នៅក្នុងភូមិភាគ បូព៌ា ក្នុងឆ្នាំ ១៩៧៨។ យោងទៅតាមសេចក្តីសម្រេចបំបែកកិច្ចដំណើរការនីតិវិធីសវនាការរបស់អង្គជំនុំជម្រះ ដែលបានចេញកាលពីខែ ឧសភា ឆ្នាំ ២០១៤ វាក៏ពាក់ព័ន្ធទៅនឹងទីតាំងឧក្រិដ្ឋកម្មមួយចំនួនផងដែរ ដូចជា នៅសហករណ៍ត្រាំកក់ និង ស-២១។ មេធាវីការពារក្តីក៏បានលើកឡើងពីការព្រួយបារម្ភទៅលើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះដែលសម្រេចស្តាប់សាក្សីលើអង្គហេតុការបោសសម្អាត ហើយដែលសាក្សីទាំងនោះត្រូវបានកំណត់ក្នុងអំឡុងពេលស៊ើបអង្កេត ក្នុងសំណុំរឿង ០០៣ និង ០០៤ ។ ការធ្វើដូច្នេះ គឺអង្គជំនុំជម្រះកំពុងតែពន្លាតយុត្តាធិការរបស់ខ្លួន លើសពី ដីកាដំណោះស្រាយដែលជាមូលដ្ឋាននៃយុត្តាធិការរបស់អង្គជំនុំជម្រះ។

មេធាវីការពារក្តី ខៀវ សំផន ក៏មានមន្ទិលសង្ស័យអំពី ថាតើអង្គជំនុំជម្រះនឹងប្រើប្រាស់ភស្តុតាងពាក់ព័ន្ធនឹងការបោសសម្អាតផ្ទៃក្នុងដល់កម្រិតណា ប្រសិនបើវាមិនស្ថិតនៅក្នុងវិសាលភាពនៃការជំនុំជម្រះផងនោះ។ ការដាក់អង្គហេតុដែលមិនមែនជាផ្នែកនៃដីកាដំណោះស្រាយ ឬ សេចក្តីសម្រេចបំបែកកិច្ចដំណើរការនីតិវិធី ប៉ុន្តែពាក់ព័ន្ធនឹងតួនាទីរបស់ជនជាប់ចោទ និងសហឧក្រិដ្ឋកម្មរួម គឺផ្ទុយពីវិធាន ៩៨(២)។

មេធាវីការពារក្តី នួន ជា យល់ស្របភាគច្រើនជាមួយនឹងសេចក្តីសន្និដ្ឋានរបស់មេធាវីការពារក្តី ខៀវ សំផន ប៉ុន្តែមិនបដិសេធទៅនឹងការបង្ហាញខ្លួនរបស់សាក្សីសម្រាប់ការបោសសម្អាតផ្ទៃក្នុងដែលត្រូវបានបញ្ជូនទៅ ស-២១ នោះទេ ដោយសារភស្តុតាងនេះពាក់ព័ន្ធយ៉ាងសំខាន់ទៅនឹងសំណុំរឿងនេះ។ មេធាវីការពារក្តី ក៏យល់ស្របផងដែរថា "ការបោសសម្អាត" គឺមិនមែនជាឧក្រិដ្ឋកម្មនោះទេ ប៉ុន្តែគឺជាព្រឹត្តិការណ៍។

សហព្រះរាជអាជ្ញាបានលើកឡើងថា ការបោសសម្អាត ទោះបីជាមិនមែនជាឧក្រិដ្ឋកម្មក៏ដោយ ប៉ុន្តែវាជាផ្នែកមួយនៃគោលនយោបាយដែលនាំឲ្យមានបទឧក្រិដ្ឋនៅទីតាំងដូចជា ស-២១ ហេតុដូចនេះគឺវាពាក់ព័ន្ធទៅនឹងការជំនុំជម្រះ។ វាក៏ពាក់ព័ន្ធផងដែរទៅនឹងការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ ខៀវ សំផន ហើយនិងគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា ក្នុងការកំណត់ខ្មាំង។

សហមេធាវីនាំមុខបានបញ្ជាក់ពីការយល់ឃើញរបស់ខ្លួនទៅលើយុត្តាធិការរបស់អង្គជំនុំជម្រះទាក់ទងនឹងការបោសសម្អាតផ្ទៃក្នុង។ មេធាវីនាំមុខបានលើកឡើងថា អង្គជំនុំជម្រះត្រូវកំណត់ត្រឹមបទឧក្រិដ្ឋដែលត្រូវបានប្រព្រឹត្តនៅ ភ្នំក្រោល អូកន្សែង ហើយនិង ស-២១ និងគោលនយោបាយបោសសម្អាតដែលបានកើតឡើងនៅភូមិភាគឧត្តរ និងភូមិភាគបូព៌ាតែប៉ុណ្ណោះ។ មេធាវីនាំមុខបានបង្ហាញថាភស្តុតាងនោះគឺពាក់ព័ន្ធនឹងតួនាទីរបស់ជនជាប់ចោទ និងសហឧក្រិដ្ឋកម្មរួម។

បន្ទាប់ពីបានស្តាប់សារណាផ្ទាល់មាត់ អង្គជំនុំជម្រះបានជូនដំណឹងដល់ភាគីថាខ្លួនកំណត់ឲ្យដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-236 ឲ្យមកផ្តល់សក្ខីកម្មនៅថ្ងៃបន្ទាប់ដោយសារអង្គជំនុំជម្រះត្រូវការពេលវេលា

ពិភាក្សាលើបញ្ហានេះ។

Reclassified

| TC No | OCIJ No | ERN (KH, ENG, FR) | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| E3/7633 | D108/27.9 | 00052417-00052440; 00863749-00863766; 00333264-00333277 | Annex 9: Interview with Huy Pan | P | 00052430 00052433 00052434 | 00863759 00863761 | - |
| E3/10090 | - | 01159537-01159557; - - | Name list of prisoners had the document | P | - | - | - |

Other documents (No Change)

| TC No | OCIJ No | ERN (KH, ENG, FR) | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| E3/2133 | D312.1.45 | 00006728-00006728; 00242285-00242285; 00250912-00250912 | The list of prisoner has been killed in brother Huy Sre's section | P | 00006728 | 00242285 | 0025091 |
| E3/1578 | D86/20 | 00178019-00178030; 00194545-00194555; 00178031-00178044 | Written Record of Interview of Duch by CIJ on 27-03-2008 | P | 00178027 | 00194552 | 00178040 |

| | | | | | | | |
|---|---|---|---|---|---|---|---|
| E3/455 | D86/7 | 00146668-00146679; 00149907-00149919; 00149932-00149945 | Written Record of Interview of Duch by CIJ on 03-10-2007 | P | 00146674 | 00149913 | 00149938 |
| E3/448 | D86/10 | 00154923-00154929; 00154906-00154913; 00154914-00154922 | Written Record of Interview of Duch by CIJ on 04-12-2007 | P | 00154928 00154929 | 00184912 | 00154921 00154922 |
| E3/226 | - | 00017147-00017160; 00183363-00183373; 00296158-00296167 | Minute of the meeting on social affairs and health on 10/6/76 | P | 00171458 | 00183372 | 00296166 |
| E3/454 | D86/6 | 00146657-00146667; 00147600-00147608; 00149920-00149931 | Written Record of Interview of Duch by CIJ on 02-10-2007 | P | 00146661 | 00147603 | 00149924 |
| E3/449 | D86/11 | 00158835-00158842; 00159552-00159559; 00158843-00158850 | Written Record of Interview of Duch by CIJ on 21-01-2008 | P | 00158840 | 00159557 | 00158848 |
| E3/357 | D120 | 00242917-00242927; 00242928-00242938; 00242939-00242948 | Written Record of Interview of Duch by CIJ on 27-11-2008 | P | 00242925 | 00242936 | 00242947 |
| E3/82 | D226 | 00398175-00398181; 00398182-00398188; 00398189-00398194 | Written Record of Confrontation with Duch on 20-10-2009 | P | 00398179 | 00398188 | 00398193 |

| ដីកា/សេចក្តីសម្រេចផ្ទាល់មាត់៖ |
| --- |
| • អនុញ្ញាតឱ្យជនជាប់ចោទ នួន ជា បន្តតាមដានកិច្ចដំណើរការនីតិវិធីសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ ហើយបង្គាប់ឱ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា ដើម្បីបន្តសវនាការពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ។<br>• បង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា និង ខៀវ សំផន ទៅកាន់មន្ទីរឃុំឃាំងវិញ និងបង្គាប់ឱ្យនាំខ្លួនពួកគាត់ត្រឡប់មកកាន់សាលសវនាការវិញឱ្យបានមុនម៉ោង ៩.00 ព្រឹក នៅថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៦ ។ |

| កាលវេលាសវនាការបន្ត |
| --- |
| សវនាការនឹងបន្តទៅថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៦ ចាប់ផ្តើមពីម៉ោង 0៩.00 ព្រឹក។ |

ភ្នំពេញ ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១៦

ក្រឡាបញ្ជី ក្រឡាបញ្ជី

ជា ស៊ីវហ៊ាង Evelyn CAMPOS SANCHEZ